# សំណួរដែលសួរញឹកញាប់

**តើសួនឧទ្យាន តំបន់កម្សាន្តអ្វីខ្លះដែលត្រូវបើក?**
គិតមកដល់ថ្ងៃទី 4 ខែមិថុនា ដីធ្លីសាធារណៈដែលគ្រប់គ្រងដោយរដ្ឋសឹងទាំងអស់បានបើកឡើងវិញសម្រាប់**បម្រើបម្រាស់ប្រចាំថ្ងៃ**។

**ការបោះជំរំ** កំពុងបើកឡើងវិញនៅក្នុងខោនធីជាច្រើនដែលបានឆ្លងទៅកាន់ដំណាក់កាលទី 2 នៃផែនការ ចាប់ផ្តើមដោយសុវត្ថិភាព របស់លោកអភិបាល Jay Inslee។

កន្លែងបញ្ចេះដំណើរការទូក និងផែសម្រាប់ទូកកម្សាន្តដែលគ្រប់គ្រងដោយរដ្ឋនៅឧទ្យានរដ្ឋនៅខោនធីដំណាក់កាលទី 2 ក៏បើកផងដែរ។

ដើម្បីស្វែងយល់ឲ្យដឹងនូវស្ថានភាពបច្ចុប្បន្ននៃកន្លែងបោះជំរំ ឧទ្យាន និងតំបន់ដីសម្រាប់កម្សាន្តដែលគ្រប់គ្រងដោយរដ្ឋដទៃទៀត សូមចូលមើល៖

- Washington State Parks — ស្ថានភាពសួនឧទ្យាន
- Washington Department of Fish and Wildlife — បញ្ជីនៃការបិទ និងការរឹតត្បិត
- Washington State Department of Natural Resources — ការបើកការកម្សាន្ត

**កំណត់សម្គាល់៖** ឧទ្យានមួយចំនួននៅខោនធីដំណាក់កាលទី 2 **អាចនឹងមិនបើក** សម្រាប់ការបោះជំរំភ្លាមៗទេ ដោយផ្អែកលើការណែនាំបង្គាប់មកពីមន្ត្រីខោនធី។ Washington State Parks គាំទ្រ និងបន្តធ្វើការជាមួយសហគមន៍ទាំងនេះ ដើម្បីស្វែងរកវិធីសាស្ត្រប្រសើរបំផុតសម្រាប់បើកឡើងវិញនូវការបោះជំរំ។

**តើខ្ញុំត្រូវការ Discover Pass ដែរឬទេ?**
មែនហើយ។ Discover Pass គឺតម្រូវឲ្យមាន ដើម្បីចតយានជំនិះរបស់អ្នកនៅតំបន់ដីសម្រាប់កម្សាន្តរបស់រដ្ឋ និងទីសម្រាប់ចូលទៅកាន់ទឹកដែលត្រូវបានគ្រប់គ្រងដោយ Washington State Parks និង Department of Natural Resources (DNR)។ ដីធ្លីទាំងនេះរួមបញ្ចូលនូវឧទ្យានរដ្ឋ ចំណុចសម្រាប់ចូលទៅកាន់ទឹក ទីបេតិកភ័ណ្ឌ តំបន់សត្វព្រៃ និងធម្មជាតិ កន្លែងសម្រាប់បោះជំរំ DNR ផ្លូវលំ និងក្បាលផ្លូវលំ និងទីខ្ពស់ដែលគ្រប់គ្រងដោយ DNR ទាំងអស់។ Discover Pass គឺតម្រូវឲ្យមាននៅឧទ្យានរដ្ឋសម្រាប់ការចូលទស្សនាប្រើប្រាស់ពេលថ្ងៃតែប៉ុណ្ណោះ។

Discover Pass ក៏តម្រូវឲ្យមានផងដែរនៅលើដីធ្លីដែលគ្រប់គ្រងដោយ Washington Department of Fish and Wildlife (WDFW)។ នេះរួមបញ្ចូលនូវតំបន់សម្រាប់ចូលទៅកាន់ទឹក និងតំបន់សត្វព្រៃ

លុះត្រាតែអ្នកមានរួចហើយនូវ Vehicle Access Pass ដែលត្រូវបានចេញដោយការទិញនូវអាជ្ញាបណ្ណបរបាញ់ ឬនេសាទដែលមានសិទ្ធិ។

## តើខ្ញុំអាចទទួលបានការពន្យារពេល ឬការបង្វិលប្រាក់ជូនវិញនៅលើ Discover Pass របស់ខ្ញុំសម្រាប់ពេលដែលដីធ្លីរដ្ឋត្រូវបានបិទដែរឬទេ?

យើងនឹងមិនបង្វិលប្រាក់ជូនវិញ ឬពន្យារពេលនៅលើ Discover Passes ឡើយ។

Discover Pass ប្រចាំឆ្នាំមានតម្លៃ $30។ តម្លៃនៃលិខិតអនុញ្ញាតឲ្យចូលពេលថ្ងៃគឺ $10 ដូច្នេះលិខិតអនុញ្ញាតឲ្យចូលប្រចាំឆ្នាំបង់ថ្លៃសម្រាប់ឲ្យខ្លួនវានៅក្នុងត្រឹមតែការចូលទស្សនាតែបីដងប៉ុណ្ណោះ។

ចែកនឹង 12 ខែ នោះគឺជាតម្លៃប្រចាំខែដែលមានចំនួន $2.50។ ដីធ្លីរដ្ឋត្រូវបានបិទពីថ្ងៃទី 23 ខែមីនា ដល់ថ្ងៃទី 5 ខែឧសភា គ្រាន់តែរយៈពេលប្រាំសប្តាហ៍ប៉ុណ្ណោះ។

សួនឧទ្យានរដ្ឋបានជួបប្រទះនឹងការបាត់បង់ចំណូលយ៉ាងគំហុកនៅរដូវស្លឹកឈើលាស់នេះ - បន្ថែមទៅលើការកាត់បន្ថយយ៉ាងលើសលុបនៅក្នុងការធ្លាក់ចុះសេដ្ឋកិច្ចដ៏ធំសម្បើមចុងក្រោយ។

យ៉ាងណាមិញ យើងសូមលើកទឹកចិត្តឲ្យអ្នករីករាយនឹង Washington state parks និងទីដីធ្លីរដ្ឋឲ្យបានញឹកញាប់នៅរដូវក្តៅនេះ និងលើសពីនេះទៀត ដើម្បីទទួលបាននូវតម្លៃដ៏អស្ចារ្យបំផុតដែលអាចមានពីលិខិតអនុញ្ញាតឲ្យចូលរបស់អ្នក។

## តើទីធ្លាលេងបើកដែរឬទេ?

ទីធ្លាលេងនៃឧទ្យានរដ្ឋត្រូវបានបិទរហូតដល់មានសេចក្តីជូនដំណឹងបន្ថែមទៀត ដើម្បីកាត់បន្ថយការរងប៉ះពាល់នឹងជំងឺ COVID-19។

## តើបន្ទប់ទឹកនឹងបើកមែនទេ?

មែនហើយ។ នៅក្នុងសួនឧទ្យានដែលបើក បន្ទប់ទឹកនឹងមាននៅក្នុងតំបន់ប្រើប្រាស់ពេលថ្ងៃដែលបើក និងតំបន់ដែលទីធ្លាបោះជំរំបើក។ បន្ទប់ទឹកអាចនឹងត្រូវបានបិទនៅទីតាំងខ្លះ និងនៅក្នុងទីធ្លាបោះជំរំដែលបិទ។

សូមត្រៀមរៀបចំខ្លួន។ សូមនាំយកសម្ភារៈបរិក្ខារការពារខ្លួនផ្ទាល់របស់អ្នក ទឹក សាប៊ូ ទឹកលាងដៃ និងក្រដាសអនាម័យ និងវេចខ្ចប់អ្វីគ្រប់យ៉ាងដែលអ្នកនាំយកចូលមកជាមួយអ្នក។

ការិយាល័យសួនឧទ្យាននៅតែបិទដដែលសម្រាប់សាធារណជន ក៏ដូចជាមជ្ឈមណ្ឌលភ្ញៀវ និងអគារសំចតផងដែរ។

## តើផែ កន្លែងចតទូក និងកំពង់ផែសម្រាប់កម្សាន្តបើកដែរទេ?

ការប្រើប្រាស់ផែត្រូវបានអនុញ្ញាត ហើយកន្លែងចតទូកគឺអាចរកបាននៅឯសួនឧទ្យានដែលបើក។ មនុស្សដែលប្រើប្រាស់ផែគួរតែអនុវត្តការរក្សាគម្លាតពីគ្នាជាមួយមនុស្សដែលមិនមែនជាផ្នែកនៃក្រុមគ្រួសាររបស់ពួកគេ។

បន្ទប់ទឹកនៅកំពង់ផែសម្រាប់កម្សាន្តរបស់រដ្ឋនឹងបើកដោយមានកម្រិតកំណត់។ សូមវេចខ្ចប់យកចេញក្រៅនូវកាកសំណល់របស់អ្នក ហើយកុំរំពឹងទុកថាមានទឹកដែលអាចផឹកបាននៅលើកោះអី។

## តើការបោះយុថ្កានឹងត្រូវបានត្រួតពិនិត្យ ឬធ្វើនិយ័តកម្មដែរឬទេ? ចុះតំបន់សំចតឆ្នេរខ្សាច់សម្រាប់ទូកពោងយ៉ាងម៉េចវិញ?

ការបោះយុថ្កានឹងត្រូវបានត្រួតពិនិត្យ និងធ្វើនិយ័តកម្មដូចដែលពួកវាត្រូវបានធ្វើដូចនោះ នៅមុនការបិទដោយសារជំងឺ COVID-19 អញ្ចឹងដែរ។ គ្មានបទបញ្ញត្តិពិសេសមានដាក់ឲ្យប្រើទេ។

## តើការបូមបញ្ចេញកាកសំណល់ពីទូកបើក និងប្រតិបត្តិការដែរឬទេ?

ការបូមបញ្ចេញកាកសំណាល់ពីទូកមួយចំនួនតូចដែលស្ថិតនៅក្នុងសួនឧទ្យានរដ្ឋគឺបើក។

ការបូមបញ្ចេញកាកសំណល់ពីទូកសឹងទាំងអស់នៅក្នុងរដ្ឋ Washington ស្ថិតនៅឯកំពង់ផែសម្រាប់កម្សាន្តសាធារណៈ ឬឯកជន។ អ្នកជិះទូកគួរតែពិនិត្យជាមួយកំពង់ផែសម្រាប់កម្សាន្ត ដើម្បីឲ្យដឹងថាតើពួកគេបើក ហើយការបូមបញ្ចេញកាកសំណល់ពីទូកនឹងប្រតិបត្តិការដែរឬទេ។ សម្រាប់ទីតាំងការបូមបញ្ចេញកាកសំណល់ពីទូករបស់រដ្ឋ Washington សូមចូលមើល៖ [parks.state.wa.us/657/Pumpout](parks.state.wa.us/657/Pumpout)

## ប្រសិនបើសួនឧទ្យានបើកតែសម្រាប់ប្រើប្រាស់ពេលថ្ងៃ តើម៉ោងប៉ុន្មានដែលសួនឧទ្យានបិទ?

សួនឧទ្យានប្រើប្រាស់ពេលថ្ងៃបិទនៅពេលព្រលប់។

## តើខ្ញុំនឹងទទួលបានការបង្វិលប្រាក់ជូនវិញសម្រាប់ការបោះជំរំរបស់ខ្ញុំ ឬការកក់ទុកការសំណាក់មួយយប់ដែរទេ?

វាអាស្រ័យលើ...

- **ភ្ញៀវទេសចរនាសម្រាកមួយយប់ដែលរងប៉ះពាល់ដោយការបិទ៖** យើងកំពុងតែទាក់ទងភ្ញៀវទេសចរនាដែលសម្រាកមួយយប់ដែលមានការកក់ទុកដែលរងប៉ះពាល់ដោយការបិទ ដើម្បីផ្តល់នូវប្រាក់បង្វិលជូនវិញគ្រប់ចំនួន។
- **ភ្ញៀវទេសចរនាទៅកាន់សួនឧទ្យានសម្រាប់បោះជំរំដែលបើក** អាចទទួលបានការបង្វិលប្រាក់ជូនវិញគ្រប់ចំនួនសម្រាប់ការស្នាក់នៅមួយយប់ ដកចោលថ្លៃឈ្នួលប្រតិបត្តិការដែលមិនអាចបង្វិលជូនវិញបានចំនួនពីរ (ថ្លៃឈ្នួលកក់ទុក $8 រហូតដល់ $10 និងថ្លៃឈ្នួលលុបចោលចំនួន $8 រហូតដល់ $10)។ ថ្លៃឈ្នួលកក់ទុកគឺ $8 ប្រសិនបើត្រូវបានធ្វើឡើងតាមអនឡាញ និង $10 ប្រសិនបើត្រូវបានធ្វើឡើងតាមទូរស័ព្ទ។

ប្រសិនបើអ្នកមានសំណួរអំពីការកក់ទុកការបោះជំរំបច្ចុប្បន្នរបស់អ្នក សូមទូរស័ព្ទទៅកាន់លេខ (888) CAMPOUT ឬ (888) 226-7688។

## ចុះបើខ្ញុំមានការកក់ទុកនៅសួនឧទ្យានដែលបច្ចុប្បន្ននេះត្រូវបានបិទសម្រាប់ការបោះជំរំវិញតើយ៉ាងម៉េចវិញ? តើពេលណាខ្ញុំនឹងដឹងថាតើការកក់ទុករបស់ខ្ញុំត្រូវបានលុបចោល?

យើងសូមអរគុណអ្នកសម្រាប់ការអត់ធ្មត់របស់អ្នកនៅពេលយើងដោះស្រាយជាមួយស្ថានការណ៍ដែលចេះតែផ្លាស់ប្តូរនេះ។ យើងដឹងថាផែនការវិស្សមកាលរបស់អ្នកគឺសំខាន់ ហើយយើងសង្ឃឹមថាអ្នកនឹងអាចបោះជំរំនៅ ឧទ្យានរដ្ឋវ៉ាស៊ីនតោន ជាទីសំណព្វចិត្តរបស់អ្នកនៅរដូវក្តៅនេះ។

ដោយសារហេតុផលនោះ យើងស្នាក់ស្ទើរក្នុងការលុបចោលការកក់ទុករហូតដល់យើងក្បែរនឹងប្រាកដថាសួនឧទ្យាននឹងមិនបើកឡើងវិញទេសម្រាប់ការបោះជំរំនៅត្រឹមកាលបរិច្ឆេទដែលអ្នកបានកក់។ ដូច្នេះហើយ អ្នកអាចនឹងមិនបានឮពីយើងទេរហូតដល់ប៉ុន្មានថ្ងៃមុនការស្នាក់នៅដែលបានរៀបផែនការទុករបស់អ្នក។

ប្រសិនបើយើងត្រូវតែលុបចោលការកក់ទុកនៅសួនឧទ្យានដែលនៅតែបិទសម្រាប់ ការបោះជំរំ យើងនឹងទាក់ទងអ្នកតាមអ៊ីមែល ហើយអ្នកនឹងទទួលបានការបង្វិលប្រាក់ជូនវិញគ្រប់ចំនួន។

សម្រាប់សំណួរជាក់លាក់អំពីការកក់ទុករបស់អ្នក សូមទាក់ទងក្រុមការងារកក់ទុករបស់យើងតាមលេខ 888-CAMPOUT (888-226-7688)។

## តើដីធ្លីរដ្ឋនឹងបិទដែរទេ ប្រសិនបើមានបញ្ហាជាមួយនឹងការប្រមូលផ្តុំហ្វូងមនុស្ស?

នៅពេលយើងបើកដីធ្លីឡើងវិញ យើងនឹងស្នើឲ្យមនុស្សម្នាទាំងឡាយបន្តអនុវត្តការរក្សាគម្លាតក្នុងសង្គម។ ប្រសិនបើយើងកត់សម្គាល់ឃើញមានការជួបជុំជាក្រុមធំៗ ឬមនុស្សម្នាមិនរក្សាគម្លាតក្នុងសង្គមទេនោះ យើងអាចនឹងត្រូវតែពិនិត្យមើលការបិទសួនឧទ្យាន ឬតំបន់នៅក្នុងសួនឧទ្យាន។

ប្រសិនបើកង្វល់ខាងសុវត្ថិភាពថ្មីទាក់ទងនឹងជំងឺ COVID-19 កើតចេញមក Washington Departments of Fish and Wildlife (WDFW) និង Natural Resources (DNR) និងសួនឧទ្យានរដ្ឋអាចនឹងបិទតំបន់ដោយមានសេចក្តីជូនដំណឹងមានកំណត់ ដើម្បីការពារសុខភាព និងសុវត្ថិភាពសាធារណៈ។

### តើខ្ញុំអាចរាយការណ៍បញ្ហាណាមួយនៃការប្រមូលផ្តុំគ្នាកកកុញ សំរាម ឬកង្វល់ដទៃផ្សេងទៀតនៃតំបន់សត្វព្រៃ ឬកន្លែងបញ្ចេះទូកចេញដំណើរទៅកាន់ WDFW យ៉ាងដូចម្តេច?

មនុស្សទាំងឡាយអាច រាយការណ៍ពីបញ្ហា នៅលើគេហរបស់ Washington Department of Fish and Wildlife បាន។

### តើខ្ញុំនៅតែអាចស្ម័គ្រចិត្តដើម្បីជួយសម្អាត និងរក្សាសួនឧទ្យានរដ្ឋក្នុងមូលដ្ឋានរបស់ខ្ញុំបានដែរទេ?

មិនមែននៅពេលនេះទេ។ យើងសូមកើតសរសើរចំពោះអ្នកស្ម័គ្រចិត្តរបស់យើង និងម៉ោងនៃការប្រឹងធ្វើការងាររបស់ពួកគេ។ យ៉ាងនេះក្តី គ្មានសកម្មភាពអ្នកស្ម័គ្រចិត្តនឹងកំពុងប្រព្រឹត្តទៅឡើយរហូតដល់មានសេចក្តីជូនដំណឹងតទៅទៀត។ សួនឧទ្យានរដ្ឋកំពុងធ្វើការដើម្បីចាប់ផ្តើមឡើងវិញនូវកម្មវិធីម្ចាស់ផ្ទះជំរំ និងកម្មវិធីអ្នកស្ម័គ្រចិត្តផ្សេងទៀតនៅពេលក្រោយមកទៀតនៅរដូវក្តៅនេះ។ សូមពិនិត្យរកមើលបច្ចុប្បន្នភាព ឬទាក់ទង Volunteer Program តាម អ៊ីមែល ឬទូរស័ព្ទទៅលេខ (360) 902-8583។

### តើពេលណាដែលផ្ទះតូចក្នុងព្រៃ និងផ្ទះតង់មូលមានគ្រោងឈើនឹងបើក?

កូនផ្ទះក្នុងព្រៃ និងតង់មូលមានគ្រោងឆ្អឹងឈើ និងជម្រកបែបស្រុកស្រែ នៅតែបិទសម្រាប់ការកក់ទុកថ្មីរហូតដល់ថ្ងៃទី 30 ខែមិថុនា។ សម្រាប់កូនផ្ទះក្នុងព្រៃដែលអាចបើកនៅក្នុងខែមិថុនា ការកក់ទុកដែលមានស្រាប់នឹងត្រូវបានផ្តល់ជូន។

### តើកន្លែងបោះជំរំជាក្រុមបើកដែរឬទេ?

ការបោះជំរំជាក្រុមត្រូវបានបិទរហូតដល់មានសេចក្តីជូនដំណឹងតទៅទៀត។

### តើផ្ទះវិស្សមកាលបើកដែរឬទេ?

ផ្ទះវិស្សមកាល ត្រូវបានបិទរហូតដល់មានសេចក្តីជូនដំណឹងតទៅទៀត។